# អ្នកតាទ្វារ និងជំនឿប្រតិបត្តិ

អ្នកតាទ្វារ ជាប្រជុំអ្នកតាដែលមានឈ្មោះផ្សេងៗ ស្ថិតក្នុងភូមិសាស្ត្រភ្នំទ្វារនៃខេត្តកំពត លើកំណាត់ផ្លូវជាតិលេខ៣ នៅក្បែរដើមផ្លូវបំបែកអង្គខ្ញុងឆ្ពោះទៅអតីតរាជធានីឧត្តុង្គ។[១] ក្នុងចំណោមអ្នកតាទាំងនោះ ក៏មានយាយម៉ៅផងដែរ ជាអមនុស្សដែលអ្នកដំណើរ និងមនុស្សផងទាំងឡាយគោរព ហើយជាពិសេសសូម្បីតែថ្នាក់ដឹកនាំខេត្ត តែងចូលអុជធូបបូជាមិនដែលរំលង។ ក្នុងពេលថ្មីៗនេះមុនថ្ងៃប្រកាសទទួលតួនាទីជាអភិបាល នៃគណៈអភិបាលខេត្តកំពត ឯកឧត្តម ម៉ៅ ធនិន និងសហការីក៏បានអញ្ជើញមកអុជធូបគោរពប្រណិប័តន៍នៅត្រង់ទីអ្នកតាទ្វារដែរ។ ជំនឿ និងការប្រតិបត្តិនេះគេឃើញមានជាប់ហូរហែតាំងពីដើមរៀងមក ទាំងក្នុងជំនឿអ្នកដំណើរ និងថ្នាក់ដឹកនាំខេត្ត ដ្បិតក្នុងអាណត្តិអភិបាលខេត្តខ្លះ លោកបានរៀបចំកសាងជាអាស្រម និងអាសនៈថ្វាយជាដើម។

ក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរដំណាលថា កាលផ្លូវជាតិលេខ៣ មិនទាន់ស្ថាបនានៅត្រង់ចំណុចអ្នកតាទ្វារមានតែផ្លូវរទេះគោកាត់ព្រៃស្រោងស្ងាត់ជ្រងំ និងប្រកបដោយសត្វព្រៃកាចសាហាវជាច្រើន។ ថ្ងៃមួយមានតាម្នាក់ឈ្មោះ "ក្រហមក" និងប្រពន្ធឈ្មោះ "យាយម៉ៅ" បានធ្វើដំណើរកាត់ព្រៃនោះ។ មកដល់ត្រង់ចំណុចភ្នំទ្វារ យាយតា និងអ្នករួមដំណើរបានលាកញ្ចប់បាយបរិភោគ ស្រាប់តែដំរីមួយហ្វូងចេញមកដេញធ្វើឱ្យម្នាក់ៗប្រឹងរត់ប្រាសយកតែអាយុរៀងខ្លួន។ ចំណែកយាយម៉ៅរត់ទៅក៏ជួបនឹងខ្លាធំមួយ ហើយត្រូវខ្លាខាំស្លាប់ទៅ។ លុះបំណេរតមក អ្នកស្រុកភូមិជិតឆ្ងាយដែលធ្វើដំណើរឆ្លងកាត់កន្លែងនោះខ្លាចរអា និងបារម្ភជួបគ្រោះថ្នាក់ ហើយម្នាក់ៗតែងតែបន់ស្រន់សុំឱ្យបានសេចក្ដីសុខសប្បាយដោយមានដាក់ជផ្កាយផ្សេងៗតាមដែលខ្លួនមាន។[២]

បើពិនិត្យលក្ខណៈភូមិសាស្ត្រត្រង់ចំណុចភ្នំទ្វារ គេឃើញថាគឺជាច្រកភ្នំពីរជួបគ្នាកើតជាជម្រាលផ្លូវចោត និងកោងបន្តិច អាចបង្កគ្រោះថ្នាក់ដល់ការបើកបរឆ្លងកាត់ទៅ

---

[១] ក្រោយស្ថាបនាជាផ្លូវក្រាលកៅស៊ូ គេហៅផ្លូវនេះថាផ្លូវលេខ៤១

[២] ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ១៩៨០: ១២៣-១៣៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មកជាយថាហេតុ។ មិនតែប៉ុណ្ណោះមាននិទានមួយទៀតដំណាលថា កាលពីរាជ្យព្រះបាទអង្គឌួង ទ្រង់បានចាត់ការធ្វើផ្លូវពីឧត្តុង្គកាត់មកកំពត លុះដល់ច្រកភ្នំទ្វារក៏កើតជំងឺចាញ់ស្លាប់មនុស្សអ្នកធ្វើការអស់ជាច្រើន។[៣] រីឯក្នុងកំណត់ហេតុធ្វើដំណើររបស់លោក អាដេម៉ា ឡឺក្លែរ (Adhémard Leclère) ជាអតីតរេស៊ីដង់ប្រចាំខេត្តកំពតសម័យបារាំងមាននិយាយអំពីទ្វារខេត្ត (porte de la province) នៃខេត្តកំពតដែលទំនងចង់សំដៅលើភ្នំទ្វារនេះដែរ។[៤] មុនទសវត្សទី៩០ គេដឹងថាទីនេះក៏ជាច្រកតែមួយគត់ដែលក្រុមឧទ្ទាមខ្មែរក្រហមឆ្លងកាត់ទៅមកដែរ ហើយពួកគេតែងបង្កអសន្តិសុខដល់អ្នកដំណើរជារឿយៗ។

បច្ចុប្បន្នស្ថានភាពផ្លូវត្រង់ច្រកភ្នំទ្វារល្អប្រសើរ តែគំនិតធ្លាប់គិតថា "ជាកន្លែងគ្រោះថ្នាក់" នៅដក់ក្នុងចិត្តអ្នកដំណើរ នាំឱ្យគេតែងចុះអុជធូបសុំសេចក្ដីសុខសុវត្ថិភាពគ្រប់ដំណើរទៅមក។ រីឯរូបសំណាកអ្នកតាតម្កល់នៅទីនេះមានច្រើន តែដូចបានបញ្ជាក់ខាងលើថាគេស្គាល់ច្បាស់គឺ "យាយម៉ៅ" ហើយគេសាងអាស្រមមួយដាច់ដោយឡែកដែរ។ ចំពោះដង្វាយដែលគេតែងថ្វាយក្រៅពីស្លាធម៌ និងចេកទុំ គឺទឹកអប់ ក្រាស កញ្ចក់ និងប្រេងម្សៅ ដ្បិតគេយល់ថាយាយម៉ៅជាអមនុស្សត្រូវការភាពស្អាត។[៥] ម្យ៉ាងទៀតគេដឹងថាដង្វាយពិសេសដែលគេតែងបូជាចំពោះយាយម៉ៅ គឺរូបអង្គជាតិបុរស ដ្បិតក្នុងនិទានថាយាយម៉ៅពុំដែលស្កប់នឹងចំណង់កាមឡើយ។[៦] ប៉ុន្តែពុំដឹងហេតុផលអ្វីឱ្យប្រាកដ ទើបនៅទីនេះគេពុំសូវឃើញមានដង្វាយពិសេសថ្វាយយាយម៉ៅ ហួរហៀរដូចនៅច្រកភ្នំពេជ្រនិល និងនៅដែនកោះតាមសមុទ្រ។ តែយ៉ាងណាក៏ដោយ ជំនឿប្រតិបត្តិអ្នកតាផ្សេងៗនៅច្រកភ្នំទ្វារ រួមទាំងយាយម៉ៅទុកប្រៀបដូចជាម្ចាស់ស្រុកប៉ែកសមុទ្រ ដែលគេត្រូវគោរពគំនាប់មុននឹងឆ្លងចេញចូលច្រកទ្វារខេត្តនេះ៕

---

[៣] សូមអានបន្ថែម៖ "អ្នកតាទ្វារ" លើតំណ៖ http://www.budinst.gov.kh/

[៤] *Adhémard Leclère 1886-1887. 10. Chaier nº10*

[៥] សូមអានបន្ថែម៖ យាយម៉ៅ និងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍ លើតំណ https://www.yosothor.org/publications/khmer-renaissance/chapter-two/Yeymoa.html

[៦] អាំង ជូលាន ២០១៩: ១-១២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព



រូបលេខ១ ច្រកភ្នំទ្វារមុនពេលជួសជុលស្ថាបនា



រូបលេខ២ គំនូរច្រកភ្នំទ្វារគូរនៅអាស្រមយាយម៉ៅ



រូបលេខ៣ អ្នកដំណើរចូលអុជធូបសុំក្តីសុខ (ខាងឆ្វេងជាអាស្រមយាយម៉ៅ)



រូបលេខ៤ រូបសំណាកយាយម៉ៅ



រូបលេខ៥ រូបសំណាកតម្កល់នៅអាស្រមចាស់



រូបលេខ៦ រូបសំណាកអ្នកតាផ្សេងៗតម្កល់នៅអាស្រមថ្មី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៧ អភិបាលខេត្តថ្មីអញ្ជើញចូលអុជធូប មុនថ្ងៃទទួលតំណែង (ប្រភព៖រដ្ឋបាលស្រុកដងទង់)



រូបលេខ៨ គ្រឿងក្រអូប និងដង្វាយផ្សេងៗ



រូបលេខ៩ រូបអង្គជាតិបុរសថ្វាយក្នុងខ្ទមតូច មួយក្បែរអាស្រមយាយម៉ៅ



រូបលេខ១០ មុខលិង្គថ្មតម្កល់ក្បែរអាស្រមយាយម៉ៅ

អរិយធម៌ខ្មែរ KHMER CIVILIZATION

# ឯកសារយោង

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

១៩៨០, ប្រជុំរឿងព្រេងខ្មែរ, ភាគ៨, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត្យ

អ្នកតាទ្វារ http://www.budinst.gov.kh/

ហ៊ួន សាវង

យាយម៉ៅ និងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍ https://www.yosothor.org/publications/khmer-renaissance/chapter-two/Yeymoa.html

អាំង-ជូលាន

២០១៩, "យាយម៉ៅ", ព្រឹត្តិបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, លេខ២ ទំ.១-១២, ភ្នំពេញ

Adhémard Leclère

1886-1887, *Voyage au Cambodge,* 10. Chaier n°10, Avril-Mai

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត